# ពិធីសារវវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គរដ្ឋបាលគយ នៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេកកម្ពុជាទៅកាន់ប្រទេសចិន

ក្នុងគោលបំណងដើម្បីជំរុញការនាំចេញផ្លែចេកស្រស់កម្ពុជាទៅកាន់ប្រទេសចិនប្រកបដោយសុវត្ថិភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា (ហៅថា MAFF) និង អគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន (ហៅថា GACC) ផ្អែកលើការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ តាមរយៈការផ្លាស់ប្តូរយោបល់ដោយភាតរភាពបានឈានទៅដល់ការឯកភាពគ្នាដូចខាងក្រោម ៖

**មាត្រា ១.-**

ប្រភេទផ្លែចេកដែលអាចនាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន មានឈ្មោះវិទ្យាសាស្ត្រថា *Musa supientum* មានឈ្មោះទូទៅថាចេក (ហៅថា ចេក)។ ចេកត្រូវតែជាចេកចាស់មិនទាន់ទុំ និងមានអាយុកាលពី១០-១១សប្តាហ៍ បន្ទាប់ពីចេញផ្កា។ ចំពោះចេកទុំ និងចេកប្រេះសំបកខូច នឹងមិនត្រូវបានអនុញ្ញាតឱ្យនាំចេញទៅប្រទេសចិនឡើយ។

**មាត្រា ២.-**

ផ្លែចេកដែលត្រូវនាំចេញទៅកាន់ប្រទេសចិនត្រូវអនុលោមទៅតាមច្បាប់បទដ្ឋានគតិយុត្តិភូតគាមអនាម័យនៃប្រទេសចិន និងកម្ពុជា និងគ្មានជាប់ជាមួយនូវសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ចូលប្រទេសចិន (សូមមើលឧបសម្ព័ន្ធ) និងមិនមានជាប់ជាមួយនូវជាង ស្លឹក និងដី និងចូលទៅកាន់ប្រទេសចិន តាមកំពង់ផែដែលបានកំណត់ដោយភាគីចិន។

រាល់សំណល់ថ្នាំកសិកម្ម និងសារធាតុពុលផ្សេងៗដែលមានក្នុងផ្លែចេកនឹងមិនឱ្យលើសពីកម្រិតសំណល់អតិបរមា (MRL) ដែលកំណត់ដោយច្បាប់ប្រទេសចិន។

**មាត្រា ៣.-**

ផ្លែចេកត្រូវប្រភពចេញពីចម្ការ និងទីតាំងវេចខ្ចប់ ដែលបានចុះបញ្ជីឈ្មោះទទួលស្គាល់ដោយ MAFF និងទទួលបានការយល់ព្រមដោយ GACC។ រាល់ឯកសារចុះបញ្ជី ត្រូវមានឈ្មោះចម្ការ អាសយដ្ឋាន និងលេខកូដសម្គាល់ សម្រាប់ធានាដល់ការប្រមូលត្រឡប់មកវិញ ក្នុងករណីផ្លែចេកមិនស្របតាមលក្ខខណ្ឌតម្រូវ ត្រូវបាននាំចេញទៅកាន់ប្រទេសចិន។ MAFF ត្រូវផ្តល់បញ្ជីទីតាំងវេចខ្ចប់ជូន GACC ជាមុន នៅមុនការចាប់ផ្តើមរដូវនាំចេញចេកទៅកាន់ប្រទេសចិន ។

**មាត្រា ៤.-**

ចម្ការចេក ត្រូវអនុវត្តតាមកម្មវិធីគ្រប់គ្រងចម្ការដែលរៀបចំដោយ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ MAFF និងជំរុញការអនុវត្តជាបណ្តើរៗនៃការអនុវត្តកសិកម្មល្អ (GAP) ដោយរួមបញ្ចូលកម្មវិធីចម្រុះគ្រប់គ្រងសមាសភាពចង្រៃដើម្បីជៀសវាង និងកាត់បន្ថយការកកើតនូវសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ចូលប្រទេសចិន និងដើម្បីធានាបានសុវត្ថិភាពភូតគាមអនាម័យតាមការតម្រូវរបស់ប្រទេសចិនរួមមាន៖ ការត្រួតពិនិត្យស្ថានភាពសមាសភាពចង្រៃឱ្យបានទៀងទាត់ និងចាត់វិធានការត្រឹមត្រូវដើម្បីកម្ចាត់សមាសភាពចង្រៃ សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម ការច្រកថង់រុំផ្លែចេកនៅក្នុងកំឡុងពេលផ្លែលូតលាស់ ប្រមូលផលមុនពេលផ្លែទុំ។

**មាត្រា ៥.-**

ទីតាំងវេចខ្ចប់ ត្រូវតែមានអនាម័យស្អាតល្អ បំពាក់ដោយឧបករណ៍លាងសម្អាត មានអាងសម្រាប់ធ្វើអនាម័យលាងសម្អាតសមាសភាពចង្រៃ។ល។ ផ្លែចេកត្រូវវេចខ្ចប់ រក្សាទុកដោយឡែកនៅក្នុងលក្ខខណ្ឌសីតុណ្ហភាពទាប។សម្ភារៈវេចខ្ចប់ផ្លែចេកត្រូវតែថ្មីនិងស្អាត។ឡាំងវេចខ្ចប់នីមួយៗត្រូវបិទសញ្ញាសម្គាល់ផលិតផល និងទីកន្លែងប្រភពដើម (ខេត្ត) ឈ្មោះនៃទីតាំងវេចខ្ចប់ ឬលេខកូដនៃការចុះបញ្ជីឈ្មោះជាដើម ជាភាសាអង់គ្លេស។ ក្នុងឡូតិ៍ទំនិញបញ្ញើនីមួយៗត្រូវតែរំលេចនូវភាសាចិន "输往中华人民共和国" ។

ការដឹកជញ្ជូនត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវអនាម័យនិងគ្មានជាប់ជាមួយនូវសមាភាពចង្រៃភូតគាមអនាម័យហាមឃាត់ចូលប្រទេសចិន និងមិនមានជាប់ជាង ស្លឹក និងដី ជាដើម។

**មាត្រា ៦.-**

MAFF ត្រូវធ្វើការត្រួតពិនិត្យចាប់ពីដំណាក់កាលដាំដុះ វេចខ្ចប់ ការទុកដាក់ និងការដឹកជញ្ជូនផ្លែចេកនាំចេញទៅកាន់ប្រទេសចិន។

ចំពោះផ្លែចេកដែលបានវេចខ្ចប់រួចមុននឹងនាំចេញ MAFF ត្រូវអនុវត្តការត្រួតពិនិត្យភូតគាមអនាម័យលើសំណាកផ្លែចេកចំនួន ២% នៃទំនិញបញ្ញើសរុប។ ក្នុងករណីចេកទុំ ឬចេកប្រេះសំបកខូច ឬមានជាប់នូវសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ចូលប្រទេសចិនត្រូវបានរកឃើញ ទំនិញបញ្ញើនោះនឹងមិនត្រូវឱ្យនាំចេញទៅប្រទេសចិនឡើយ។

ចំពោះទំនិញបញ្ញើដែលគោរពតាមលក្ខខណ្ឌតម្រូវរបស់ប្រទេស MAFF ត្រូវចេញវិញ្ញាបនបត្រភូតគាមអនាម័យស្របតាមស្តង់ដារអន្តរជាតិស្តីពីវិធានការភូតគាមអនាម័យលេខ១២ (ISPM No.12) ផ្តល់នូវលេខកុងតឺន័រ ឈ្មោះទីតាំងវេចខ្ចប់ ឬលេខកូដចុះបញ្ជីព្រមទាំងបញ្ជាក់នៅក្នុងប្រតិវេទន៍បន្ថែមថា "ទំនិញបញ្ញើបានអនុលោមតាមពិធីសារនៃលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ ការនាំចេញផ្លែចេកពីកម្ពុជាទៅកាន់ប្រទេសចិននិងគ្មានជាប់ជាមួយនូវសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ចូលប្រទេសចិន "។

MAFF ត្រូវផ្តល់គំរូវិញ្ញាបនបត្រភូតគាមអនាម័យជូនទៅ GACC ដើម្បីជាការបញ្ជាក់ និងកំណត់ត្រា។

cwP

**មាត្រា ៧.-**

មន្ត្រីមានសមត្ថកិច្ច GACC នឹងចុះធ្វើអធិការកិច្ច និងត្រួតពិនិត្យភូតគាមអនាម័យនៅពេលដែលផ្លែចេកបានមកដល់កំពង់ផែប្រទេសចិន។

ប្រសិនបើរកឃើញថា ផ្លែចេកត្រូវបាននាំចេញពីទីតាំងវេចខ្ចប់ដែលមិនមានការទទួលស្គាល់ដោយ GACC ឬផ្លែចេកនោះ ទុំ ឬប្រេះ ឬជាប់ជាង ឬស្លឹក ឬដី ជាដើម ទំនិញបញ្ញើនោះនឹងត្រូវហាមឃាត់មិនអនុញ្ញាតឱ្យចូលប្រទេសចិនឡើយ។

ប្រសិនបើរកឃើញមានសមាសភាពចង្រៃភូតគាមអនាម័យណាមួយដែលមានចែងក្នុងបញ្ជីនៃឧបសម្ព័ន្ធ ឬសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ផ្សេងទៀត ទំនិញបញ្ញើនឹងត្រូវបានបដិសេធមិនអនុញ្ញាតឱ្យនាំចូល ឬបំផ្លាញចោល ឬធ្វើការរម្ងាប់សមាសភាពចង្រៃប្រកបដោយប្រសិទ្ធភាព ។

GACC នឹងធ្វើសេចក្តីជូនដំណឹងទៅ MAFF អំពីការរកឃើញនូវប្រភេទសមាសភាពចង្រៃ លេខកូដវិញ្ញាបនបត្រភូតគាមអនាម័យ លេខកូដចុះបញ្ជីនៃទីតាំងវេចខ្ចប់ និងលេខកុងតឺន័រ។ ដោយផ្អែកតាមស្ថានភាពជាក់ស្តែងនេះ ការនាំចូលផ្លែចេកពីចម្ការ និង/ឬទីតាំងវេចខ្ចប់ដែលពាក់ព័ន្ធនឹងត្រូវផ្អាក។ MAFF ត្រូវចុះស្រាវជ្រាវ ត្រួតពិនិត្យ និងចាត់វិធានការកែលម្អរហូតដល់មានចំណាត់ការសមស្រប និងទទួលស្គាល់ដោយ GACC។

ប្រសិនបើទំនិញបញ្ញើនាំចូលទៅប្រទេសចិនមានផ្ទុកសំណល់ថ្នាំកសិកម្ម ឬសារធាតុពុលលើសពីកម្រិតសំណល់អតិបរមា (MRL) ទំនិញបញ្ញើទាំងនោះមិនអនុញ្ញាតឱ្យនាំចូល ឬត្រូវបំផ្លាញចោល។ GACC នឹងជូនដំណឹងទៅ MAFF ។ ដោយផ្អែកតាមស្ថានភាពជាក់ស្តែងនេះ ការនាំចូលផ្លែចេកពីចម្ការ ឬទីតាំងវេចខ្ចប់ដែលពាក់ព័ន្ធនឹងត្រូវផ្អាក ។ MAFF ត្រូវចុះស្រាវជ្រាវ និងត្រួតពិនិត្យវិធានការកែលម្អរហូតដល់មានចំណាត់ការសមស្រប និងទទួលស្គាល់ដោយ GACC។

**មាត្រា ៨.-**

មុននឹងចាប់ផ្តើមនាំចេញទៅកាន់ប្រទេសចិន GACC នឹងបញ្ជូនមន្ត្រីអធិការកិច្ចមកកម្ពុជា ដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃលើការគ្រប់គ្រងនៃការដាំដុះដំណាំចេក ការវេចខ្ចប់ ទីកន្លែងរក្សាទុក និងការដឹកជញ្ជូន និងការប្រមូលត្រឡប់មកវិញ និងប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យនាំចេញ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងការត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងវេចខ្ចប់។

ភាគីអ្នកនាំចេញនឹងត្រូវទទួលបន្ទុករាល់ការចំណាយរួមមាន ការធ្វើដំណើរ ការស្នាក់នៅ និងការចំណាយក្នុងពេលរស់នៅក្នុងប្រទេសកម្ពុជា។ MAFFត្រូវផ្តល់ធនធានមនុស្ស និងជំនួយបច្ចេកទេសសម្រាប់អធិការកិច្ចរបស់ GACC។ ក្នុងករណីចាំបាច់ GACC និង MAFF អាចបង្កើតជាក្រុមអធិការកិច្ចបាន។

**មាត្រា ៩.-**

GACC នឹងរៀបចំការវិភាគហានិភ័យបន្ថែម ដោយផ្អែកលើការកកើតឡើងជាថ្មីនៃសមាសភាពចង្រៃនៅក្នុងប្រទេសកម្ពុជា និងការរកឃើញនូវការភ្ជាប់ជាមួយនូវសមាសភាពចង្រៃនៅច្រកចូលកំពង់ផែចិន និងពិភាក្សាជាមួយ MAFF ពីការកែសម្រួលបញ្ជីសមាសភាពចង្រៃភូតគាមអនាម័យ និងវិធានការ

## ឧបសម្ព័ន្ធ

# បញ្ជីសមាសភាពចង្រៃតូតតាមអនាម័យហាមឃាត់ចូលប្រទេសចិន

# The List of Quarantine Pests Concerned By China

1. *Bactrocera dorsalis* (Hendel)
2. *Bactrocera dorsalis* species complex
3. *Chaetanaphothrips signipennis* (Bagnall)
4. *Dysmicoccus neobrevipes* (Beardsley)
5. *Pseudococcus jackbeardsleyi* Gimpel &Miler
6. *Fusarium oxysporum* f.sp. *cubense* ( non-Chinese races )
7. *Mycosphaerella musicola* R.Leach
8. *Ralstonia solanacearum* race 2

ភូតគាមអនាម័យដែលពាក់ព័ន្ធ។

ភាគីទាំងពីរព្រមព្រៀងគ្នាថា ត្រូវពិភាក្សារកវិធានការដោះស្រាយដោយសន្តិវិធីនូវជម្លោះនានាដែលកើតមានឡើងក្នុងកំឡុងពេលនៃការអនុវត្តពិធីសារនេះ។

ពិធីសារនេះនឹងចូលធរមានចាប់ពីថ្ងៃដែលបានចុះហត្ថលេខា និងមានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ (០៣ឆ្នាំ)។ ពិធីសារនេះនឹងអាចពន្យាពេលដោយស្វ័យប្រវត្តិបាន០៣ឆ្នាំបន្តទៀត បើគ្មានភាគីណាមួយបានធ្វើការជូនដំណឹងជាលាយល័ក្ខអក្សរទៅដល់ភាគីមួយទៀត អំពីបំណងក្នុងការកែប្រែ ឬបញ្ចប់ពិធីសារនេះក្នុងរយៈពេលយ៉ាងហោចណាស់០៦ខែ មុនកាលបរិច្ឆេទផុតកំណត់។

ធ្វើនៅភ្នំពេញ ថ្ងៃទី...០២...ខែមីនា ឆ្នាំ២០១៨... ជាបីភាសាគឺ ខ្មែរ ចិន និងអង់គ្លេស ដែលមានតម្លៃស្មើគ្នា។

ក្នុងករណីកើតមានភាពមិនស្របគ្នាក្នុងការបកស្រាយឯកសារពិធីសារនេះ ត្រូវយកឯកសារភាសាអង់គ្លេសធ្វើជាគោល។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**នៃព្រះរាជាណាចក្រកម្ពុជា**
**រដ្ឋមន្ត្រី**

**អគ្គរដ្ឋបាលគយ**
**នៃសាធារណរដ្ឋប្រជាមានិតចិន**
**តំណាងរដ្ឋមន្ត្រី**